# អត្ថបទ

# ស្ដីពី

# នីតិវិធី

# នៃ

# ការដោះស្រាយវិវាទរដ្ឋបាល


## រៀបរៀងដោយ៖ លោក ជួប មិតមេរឬទ្ធិ



**បណ្ណាល័យច្បាប់**-Law Library

lawlibrarysite.wordpress.com

# មាតិកា


១.សេចក្ដីផ្ដើម..........................................................០១

២. ការដោះស្រាយតាមនីតិវិធីរដ្ឋបាលក្រៅវិវាទ....................០៣

២.១ អ្វីទៅជាការដោះស្រាយវិវាទតាមផ្លូវរដ្ឋបាល..........០៣

២.២ នីតិវិធីដោះស្រាយវិវាទតាមផ្លូវរដ្ឋបាលដោយផ្អែក លើក្របខ័ណ្ឌគតិយុត្តបច្ចុប្បន្ន....................................០៤

ក. ការដាក់ពាក្យបណ្ដឹង..............................................០៤

ខ. ការទទួលពាក្យបណ្ដឹង...........................................០៤

គ. ការត្រួតពិនិត្យពាក្យបណ្ដឹង....................................០៥

ឃ. ការអង្កេតស្រាវជ្រាវ..............................................០៥

ង. ការសន្និដ្ឋាន និងពិនិត្យវាយតម្លៃ..........................០៦

ច. ថេរវេលានៃការដោះស្រាយ....................................០៦

ឆ. ការពិភាក្សារបាយការណ៍ និងការបញ្ជូនដើម្បីសម្រេច ចុងក្រោយ........................................................................០៧

៣. ការដោះស្រាយតាមនីតិវិធីរដ្ឋបាលវិវាទ............................០៧

៣.១ នីតិវិធីដោះស្រាយតាមយុត្តាធិការ..............................០៧

៣.១.១ វគ្គដំបូង ឬការជំនុំជម្រះលើកទីមួយ.............០៧

ក. ពាក្យបណ្ដឹង......................................................០៨

ខ. ការផ្សះផ្សា.............................................................០៩

គ. ការអង្កេតស៊ើបសួរ.............................................១០

ឃ. ដំណើរការជំនុំជម្រះ...........................................១០

៣.១.២ វគ្គបន្ទាប់ពីជំនុំជម្រះលើកដំបូង....................១០

៣.១.៣ ការអនុវត្តសេចក្ដីសម្រេច................................១០

៣.២ នីតិវិធីដោះស្រាយតាមយុត្តាធិការពិសេស...............១១

៣.២.១ វិវាទទាក់ទងនឹងការបោះឆ្នោត....................១១
ក. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា........១១
ខ. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ.......................................................១១
៣.២.២ វិវាទទាក់ទងនឹងពាណិជ្ជកម្ម......................១២
៣.២.៣ វិវាទទាក់ទងនឹងបញ្ហាអគ្គីសនី...................១២
៤. សន្និដ្ឋាន ...............................................................១២

# ចំណោទស្រាយ

**ប្រធានបទ៖** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា អំណាចតុលាការគ្រប់ដណ្តប់លើគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។

ចូរធ្វើការបង្ហាញអំពីនីតិវិធីនៃការដោះស្រាយវិវាទរដ្ឋបាលផ្អែកតាមក្របខ័ណ្ឌគតិយុត្តបច្ចុប្បន្ន។

## ១. សេចក្តីផ្តើម

**ក. និយមន័យវិវាទរដ្ឋបាល៖** វិវាទរដ្ឋបាល គឺជាវិវាទដែលកើតឡើងរវាងអាជ្ញាធរសាធារណៈ និងប្រជាពលរដ្ឋ ឬរវាងនីតិបុគ្គលសាធារណៈ និងនីតិបុគ្គលសាធារណៈ ឬរវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ។ នៅក្នុងទំនាក់ទំនងរវាងអាជ្ញាធរសាធារណៈ និងប្រជាជន អាចនឹងធ្វើឱ្យកើតមាននូវទំនាស់ជាធម្មតា ពីព្រោះវាជាទំនាក់ទំនងរវាងការប្រើប្រាស់អំណាចសាធារណៈ និងការប្រើប្រាស់សិទ្ធិរបស់ប្រជាជន។

**ខ. មូលហេតុនៃវិវាទរដ្ឋបាល និងកម្មវត្ថុនៃឧបាស្រ័យ**

ការប្រើប្រាស់អំណាចសាធារណៈរបស់អាជ្ញាធររដ្ឋបាល ជាពិសេសអំពើ ឬសកម្មភាព និងសេចក្តីសម្រេចរដ្ឋបាល អាចបណ្តាលឱ្យកើតមាន៖

- អនីត្យានុកូលភាព
- បញ្ហាអសកម្ម (រដ្ឋបាលមិនអនុវត្តសមត្ថកិច្ចជាកាតព្វកិច្ចរបស់ខ្លួន)
- ការរំលោភអំណាច ឬការប្រើអំណាចផ្តេសផ្តាស (រដ្ឋបាលប្រើអំណាចឆន្ទានុសិទ្ធិហួសព្រំដែន)
- ព្យសនកម្ម

ទាំងអស់នេះ គឺជាមូលហេតុដែលបង្កឱ្យមានជាវិវាទរដ្ឋបាល។ ដូចនេះ សេចក្តីសម្រេចរដ្ឋបាល (ដែលរួមមាន កិច្ចឯកតោភាគី និងកិច្ចសន្យារដ្ឋបាល) សារាចរ ឬសេចក្តីណែនាំ ដែលមានខ្លឹមសារបង្កើតបន្ថែម បន្ថយ ឬកែប្រែស្ថានភាពគតិយុត្តិ (មានន័យថា ជាសារាចរ ឬសេចក្តីណែនាំទាំងឡាយណាដែលមានចរិតជាសេចក្តីសម្រេចរដ្ឋបាល) និងការដាក់កំហិត ឬដាក់បញ្ហា "បទបញ្ជា" ទាំងឡាយណាដែលមានលក្ខណៈអនីត្យានុកូល មានភាពអសកម្ម មានការរំលោភអំណាច ឬបង្កឱ្យមានព្យសនកម្ម គឺសុទ្ធតែជាកម្មវត្ថុនៃការធ្វើឧបាស្រ័យ។

សរុបសេចក្តីមក គេធ្វើឧបាស្រ័យក្នុងគោលដៅដើម្បី៖

- សុំកែប្រែ និរាករណ៍ ឬមោឃភាព សេចក្តីសម្រេចរបស់រដ្ឋបាល និង/ឬ
- សុំសំណងរដ្ឋបាល ។

**គ. ទោស ឬទណ្ឌកម្មរដ្ឋបាល**

ទណ្ឌកម្មខាងព្រហ្មទណ្ឌ រដ្ឋប្បវេណី និងរដ្ឋបាល គឺមានភាពស្វយ័តរវាងគ្នា។ ចំពោះទណ្ឌកម្មខាងរដ្ឋបាល អាចមានជាអាទិ៍ ការស្តីបន្ទោសជាទូន្មានផ្ទាល់មាត់ ការស្តីបន្ទោសដោយមានចំណារក្នុងលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំតាមវិធានការវិន័យ ការលុបឈ្មោះចេញពីតារាងឡើងថ្នាក់ ឬឋានន្តរសក្តិក្នុងរយៈពេលមួយកំណត់ ការដាក់ឱ្យទំនេរគ្មានបៀវត្សមិនលើសពីមួយឆ្នាំ ការបន្ថយឋានន្តរសក្តិ ឬថ្នាក់ (មួយថ្នាក់ ឬច្រើនថ្នាក់)

ការបង្ខំឱ្យចូលនិវត្តន៍មុនកំណត់ បណ្តេញចេញពីតំណែងរាជការ ការបង់ផាកពិន័យដែលធ្វើខុសអំពីច្បាប់ ការតម្រូវឱ្យផ្តល់សំណងជួសជុលលើការខូចខាតដែលបណ្តាលមកពីរដ្ឋ ការតម្រូវឱ្យផ្តល់សំណងជួសជុលលើការខូចខាតដែលបណ្តាលមកពីឯកជនចំពោះរដ្ឋ ។ល។

**ឃ. តើអ្នកណាខ្លះអាចធ្វើបណ្តឹងនេះបាន? តើអ្វីជាលក្ខខណ្ឌដើម្បីទទួលតាមផ្លូវច្បាប់នូវគុណសម្បត្តិជាអ្នកប្តឹង?**

តាមមាត្រា៣៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ"។ មានន័យថា ៖ ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិប្តឹងតវ៉ា ប្តឹងបរិហារ និងលើកមតិស្នើសុំដល់អង្គការរដ្ឋណាមួយក៏បាន អំពីអំពើខុសឆ្គង និងគោលនយោបាយ ឬច្បាប់ ឬសេចក្តីសម្រេចរដ្ឋបាលដែលប្រព្រឹត្តទៅដោយអង្គការរដ្ឋ អង្គការសង្គម ឬបុគ្គលណាមួយនៃអង្គការទាំងនោះ ដែលបង្កអន្តរាយដល់ផលប្រយោជន៍រដ្ឋ ផលប្រយោជន៍របស់សមូហភាព ឬផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋអាចប្តឹងតវ៉ាំងអំពីការមិនស្របច្បាប់នៃសេចក្តីសម្រេចទាំងឡាយរបស់រដ្ឋបាល ហើយទាមទារសំណងដើម្បីធ្វើការជួសជុលការខូចខាត ដែលខ្លួនបានទទួលអំពីសកម្មភាពទាំងឡាយរបស់រដ្ឋបាល ក្នុងន័យយ៉ាងជ្រាលជ្រៅ និងទូលំទូលាយ។

លក្ខណៈសម្បត្តិរបស់ភាគី ឬប្រធាននៃបណ្តឹងៈ

- រូបវន្តបុគ្គលៈ សំដៅទៅលើបុគ្គលម្នាក់ៗដែលមានគុណសម្បត្តិដើម្បីធ្វើបណ្តឹង ដូចដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១៦ ។ មានន័យថា បុគ្គលដែលអាចធ្វើបណ្តឹងបានគឺជាជនទាំងឡាយណាដែលមិនត្រូវបានកម្រិតសមត្ថភាព។ ជនដែលត្រូវបានកម្រិតសមត្ថភាពសំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ ដែលជនទាំងអស់នេះមិនអាចធ្វើបណ្តឹងបានឡើយ។
- តំណាងរបស់អ្នកប្តឹងៈ អាចជាមេធាវីម្នាក់ ឬច្រើននាក់ ប៉ុន្តែជាគោលការណ៍មេធាវីម្នាក់ក្នុងចំណោមមេធាវីជ្រើសរើសដោយអ្នកប្តឹង នឹងដើរតួនាទីជាតំណាងរបស់ខ្លួន។ អ្នកតំណាងនេះមានកាតព្វកិច្ចធានាដល់អ្នកដែលប្តឹងនូវការផ្តល់ឱ្យកិច្ចការពារខ្លួនប្រកបដោយវិជ្ជាជីវៈក៏ដូចជាការធានាដំណើរប្រព្រឹត្តទៅផ្នែកយុត្តិធម៌ប្រកបដោយភាពល្អប្រសើរ។ ប្រសិនបើភាគីណាមួយមិនពេញចិត្តនឹងការប្រព្រឹត្តទៅរបស់មេធាវី នោះភាគីអាចដកហូតសិទ្ធិតំណាងមកវិញបាន។
- នីតិបុគ្គលសាធារណៈ ដែលរួមរដ្ឋ សមូហភាពដែនដី (ឬរដ្ឋបាលថ្នាក់ក្រោមជាតិ) និងគ្រឹះស្ថានសាធារណៈ (គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ) ។
- នីតិបុគ្គលឯកជនៈ សំដៅទៅនីតិបុគ្គលឯកជនដែលស្វែងរកប្រាក់ចំណេញ (ក្រុមហ៊ុន) និងនីតិបុគ្គលឯកជនដែលមិនស្វែងរកប្រាក់ចំណេញ (អង្គការ)។

**ច. តើអ្នកណាមានសមត្ថកិច្ចដោះស្រាយបណ្តឹងទាំងនេះ? ឬបណ្តឹងទាក់ទងនឹងវិវាទរដ្ឋបាលអាចដោះស្រាយតាមវិធីណាខ្លះ?**

ទាក់ទងទៅនឹងបណ្ដឹងតវ៉ាខាងលើ គឺតុលាការជាអ្នកសមត្ថកិច្ចក្នុងការដោះស្រាយ ដូចមានចែងក្នុងមាត្រា៣៩ នៃរដ្ឋធម្មនុញ្ញ វាក្យខណ្ឌទី២ "...ការដោះស្រាយបណ្ដឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ"។ ប៉ុន្តែនិយាយជារួម សម្រាប់រឿងក្ដីរដ្ឋបាល តើស្ថាប័នណាមួយមានសមត្ថកិច្ចដោះស្រាយ?

តាមមាត្រា១២៨ថ្មី (មាត្រា១០៩ចាស់) កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញបានចែងថា "...អំណាចតុលាការគ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង..."។ ដូចនេះ ច្បាប់កំពូលរបស់កម្ពុជាបានប្រគល់អំណាចនេះ ឱ្យទៅតុលាការក្នុងការដោះស្រាយគ្រប់រឿងក្នុងទាំងអស់ ក្នុងនោះរួមទាំងរឿងក្ដីរដ្ឋបាលផង។ មានន័យថា ការដោះស្រាយរឿងក្ដីរដ្ឋបាល គឺជាសមត្ថកិច្ចរបស់តុលាការ ដែលរួមមានសាលាដំបូងរាជធានីខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល[1]។ ម្យ៉ាងទៀត តាមមាត្រា១២៩ថ្មី (មាត្រា១១០ចាស់) នៃរដ្ឋធម្មនុញ្ញ បានកំណត់ថា "...មានតែចៅក្រមទេដែលមានសិទ្ធិជំនុំជម្រះ..." ហើយមាត្រា១៣០ថ្មី (មាត្រា១១១ចាស់) នៃរដ្ឋធម្មនុញ្ញក៏បានចែងថា "គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ"។ ប៉ុន្តែយើងសង្កេតឃើញថា មានអញ្ញត្រកម្មសម្រាប់ករណីខ្លះ ជាក់ស្ដែងក្នុងមាត្រា១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញ គឺបានប្រគល់អំណាចក្នុងការដោះស្រាយវិវាទទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឱ្យទៅក្រុមប្រឹក្សាធម្មនុញ្ញ។

ដូចគ្នាដែរ គេឃើញមានគោលការណ៍នៃការផ្ដល់លទ្ធភាពឱ្យប្រើប្រាស់ឧប្រាស័យរដ្ឋបាល មុននឹងធ្វើឧបាស្រ័យយុត្តាធិការ។ មិនតែប៉ុណ្ណោះ គេក៏ឃើញមានកិច្ចសន្យា និងច្បាប់យថាប្រភេទមួយចំនួន បានបង្កើតកាតព្វកិច្ចក្នុងការធ្វើឧបាស្រ័យបឋម ដើម្បីដោះស្រាយរឿងក្ដីរដ្ឋបាលតាមផ្លូវរដ្ឋបាលជាមុនសិន ដោយមិនអនុញ្ញាតឱ្យធ្វើឧបាស្រ័យយុត្តាធិការដោយភ្លាមតែម្ដងនោះទេ។ មូលហេតុ គឺដោយសារវិធីដោះស្រាយវិវាទតាមផ្លូវរដ្ឋបាលនាំឱ្យគេអាចបញ្ចប់បញ្ហាដោយការសម្រុះសម្រួល អាចអនុញ្ញាតឱ្យអាជ្ញាធររដ្ឋបាលមានឱកាសពិនិត្យឡើងវិញលើកាលានុវត្តភាព ឬសមធម៌ ផងដែរ។ ប៉ុន្តែ ការដោះស្រាយនេះមិនបិទផ្លូវតវ៉ាទៅតុលាការនោះទេ មានន័យថា ឧបាស្រ័យតាមផ្លូវរដ្ឋបាលមិននាំឱ្យរលត់សិទ្ធិធ្វើឧបាស្រ័យយុត្តាធិការឡើយ។

ដូចនេះការដោះស្រាយវិវាទរដ្ឋបាល អាចធ្វើឡើងតាម (១) ផ្លូវរដ្ឋបាលខ្លួនឯង ដែលគេហៅថា ការដោះស្រាយតាមនីតិវិធីរដ្ឋបាលក្រៅវិវាទ និង (២) ផ្លូវតុលាការ ដែលគេហៅថា ការដោះស្រាយតាមនីតិវិធីយុត្តាធិការ។

## ២. ការដោះស្រាយតាមនីតិវិធីរដ្ឋបាលក្រៅវិវាទ (ឬនីតិវិធីតាមផ្លូវរដ្ឋបាល)

### ២.១ អ្វីទៅជាការដោះស្រាយវិវាទតាមផ្លូវរដ្ឋបាល

ជាការត្រួតពិនិត្យសេចក្ដីសម្រេច អំពើ ឬសកម្មភាពរបស់រដ្ឋបាលដោយរដ្ឋបាលខ្លួនឯង។ ការត្រួតពិនិត្យនេះ មានពីរបែប គឺការជួបជាមួយរដ្ឋបាលសាមី (រដ្ឋបាល/អាជ្ញាធរដែលចេញសេចក្ដីសម្រេច ឬធ្វើអំពើ) និងការជួបជាមួយរដ្ឋបាល ឬអាជ្ញាធរដែលមានឋានានុក្រមខ្ពស់ជាងរដ្ឋបាលសាមី (ឧទាហរណ៍ រដ្ឋបាលសាមីជាអភិបាលស្រុក នោះរដ្ឋបាលថ្នាក់លើ គឺអភិបាលខេត្ត រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬនាយករដ្ឋមន្ត្រីតែម្ដង) ដើម្បីបង្ហាញការពិត ឬសុំការសម្របសម្រួល ឬសុំការកែសម្រួល ដោយបញ្ជាក់ពីមូលហេតុ ចាំបាច់នានា ដែលអាចជាភស្តុតាង មនោសញ្ចេតនា ឬក្នុងន័យមនុស្សធម៌ ។ល។ និង។ល។

[1] មាត្រា១នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដីនៃរដ្ឋកម្ពុជា ហៅថា តុលាការខេត្ត/ក្រុង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ បច្ចុប្បន្ន ច្បាប់នេះនៅមានអនុភាពអនុវត្តជាធរមាន។

ការប្រើមធ្យោបាយត្រួតពិនិត្យរដ្ឋបាល អាចផ្តល់នូវគុណសម្បត្តិមួយចំនួន ដូចជា មិនចាំបាច់ចំណាយលុយលើមេធាវី មិនបាច់បង់ថ្លៃបណ្តឹង អាចបញ្ជាក់មូលហេតុចាំបាច់ក្នុងន័យមនោសញ្ចេតនា ឬមនុស្សធម៌ដែលមិនតឹងរឹងដូចផ្លូវតុលាការ ហើយមានភាពលឿនរហ័ស។ ប៉ុន្តែ មធ្យោបាយនេះថ្នាក់លើអាចសម្រេចមិនចាត់ការ ឬមិនដោះស្រាយ ហើយវាគ្មានបែបបទត្រឹមត្រូវទេ។ ផ្ទុយទៅវិញ យន្តការតាមតុលាការ (យុត្តាធិការ) គឺត្រូវតែមានការដោះស្រាយ និងការសម្រេចតាមផ្លូវច្បាប់ គ្រាន់តែថាត្រូវចំណាយថវិកា និងប្រើពេលយូរ។

ដូចនេះ យើងឃើញថា ការដោះស្រាយវិវាទរដ្ឋបាលតាមផ្លូវរដ្ឋបាល អាចធ្វើឡើងតាមពីររបៀប គឺៈ

- ការដោះស្រាយដោយអាជ្ញាធររដ្ឋបាលសាមី
- ការដោះស្រាយដោយអាជ្ញាធររដ្ឋបាលឋានានុក្រម។

## ២.២ នីតិវិធីដោះស្រាយវិវាទតាមផ្លូវរដ្ឋបាលដោយផ្អែកលើក្របខ័ណ្ឌគតិយុត្តបច្ចុប្បន្ន

ក្របខ័ណ្ឌគតិយុត្តបច្ចុប្បន្ន ដែលគេអាចយកមកប្រើដើម្បីធ្វើការដោះស្រាយវិវាទតាមផ្លូវរដ្ឋបាល គឺច្បាប់ស្តីពីការពិនិត្យ និងការដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារ និងច្បាប់ ឬបទដ្ឋានគតិយុត្តយថា-ប្រភេទមួយចំនួនទៀត ដូចជា ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អនុក្រឹត្យស្តីពីនីតិវិធីនៃការដាក់វិន័យចំពោះមន្ត្រីរាជការស៊ីវិល... ។ នីតិវិធីដោះស្រាយវិវាទតាមផ្លូវរដ្ឋបាលដោយផ្អែកតាមក្របខ័ណ្ឌច្បាប់បច្ចុប្បន្ននេះ មានដូចខាងក្រោមៈ

### ក. ការដាក់ពាក្យបណ្តឹង

ពាក្យបណ្តឹងអាចសរសេរជាលាយលក្ខណ៍អក្សរ ឬប្តឹងផ្ទាល់មាត់ក៏បាន ករណីអ្នកប្តឹងមិនចេះអក្សរ[2]។ គ្មានគំរូ ឬរបៀបសរសេរណាមួយសម្រាប់ពាក្យបណ្តឹងឡើយ។ អ្នកប្តឹងគួរស្វែងយល់ឱ្យបានច្បាស់អំពីវិវាទដែលខ្លួនកំពុងកើតមាន ដើម្បីដាក់ពាក្យបណ្តឹង ឬធ្វើការប្តឹងឱ្យចំស្ថាប័ន ឬអង្គភាពដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទនោះ។ ឧទាហរណ៍ វិវាទាក់ទងនឹងមុខងារសាធារណៈ ត្រូវប្តឹងទៅគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងមុខងារសាធារណៈ ដែលមានរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈជាប្រធាន វិវាទទាក់ទងនឹងម៉ាកពាណិជ្ជកម្ម ត្រូវដាក់ពាក្យបណ្តឹងនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជ-កម្ម ។ល។

### ខ. ការទទួលពាក្យបណ្តឹង

ក្នុងការទទួលពាក្យបណ្តឹង ស្ថាប័ន ឬអង្គភាពរដ្ឋត្រូវពិនិត្យពាក្យបណ្តឹងនោះឱ្យបានច្បាស់លាស់ ថាតើវាជាបណ្តឹងស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនដែរ ឬទេ? ប្រសិនបើពិនិត្យឃើញថា ការបណ្តឹងនោះមិនស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនដោះស្រាយ គឺត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅស្ថាប័នដែលមានសមត្ថកិច្ច ដើម្បីដោះស្រាយ។ ដូចនេះ អ្នកទទួលបណ្តឹង ត្រូវញែកឱ្យដាច់ថាតើរឿងក្តីណាជាសមត្ថកិច្ច ហើយរឿងក្តីណាដែលអសមត្ថកិច្ច រួចត្រូវណែនាំ និងបញ្ជូនទៅតាមរយៈ និងតាមប្រភេទរឿង ជៀសវាងទទួលយកទាំងបំពាន ឬទាំងកំហុស។

[2] យោងតាមមាត្រា២នៃច្បាប់ស្តីពីការពិនិត្យ និងការដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារៈ ប្រជាពលរដ្ឋអាចផ្តល់ព័ត៌មាន ឬមកជួបនឹងស្ថាប័នរដ្ឋដោយផ្ទាល់ ដើម្បីធ្វើការប្តឹងតវ៉ា និងប្តឹងបរិហារ។

ការិយាល័យទទួលពាក្យបណ្តឹង ឬសមត្ថកិច្ចទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ឬអ្នកប្តឹង ត្រូវយកចិត្តទុកដាក់ក្នុងការពិនិត្យវាយតម្លៃដើម្បីធ្វើការបែងចែកទៅតាមជំនាញ និងទៅតាមទិសដៅ និងត្រូវចុះលេខក្នុងសៀវភៅចុះលេខចូល បោះត្រា និងចុះលេខចូលលើស្រោមសំបុត្រ ឬចុះលើពាក្យបណ្តឹង រួចបញ្ជូនទៅការិយាល័យជំនាញ ឬសមត្ថកិច្ចជំនាញដើម្បីត្រួតពិនិត្យ។ ក្នុងករណីអ្នកប្តឹងនិយាយផ្ទាល់មាត់ ការិយាល័យទទួលពាក្យបណ្តឹង ត្រូវណែនាំឱ្យអ្នកចង់ប្តឹងនូវរបៀបសរសេរពាក្យបណ្តឹង ឬអាចសរសេរឱ្យជនរងគ្រោះបាន តែត្រូវអានឱ្យអ្នកប្តឹងស្តាប់ រួចចុះហត្ថលេខាលើពាក្យបណ្តឹងក្នុងនាមខ្លួនសរសេរ ជៀសវាងបំភាន់ផ្សេងៗ (ក្នុងករណីអ្នកប្តឹងគ្មានលទ្ធភាពក្នុងការសរសេរ)។

**គ. ការត្រួតពិនិត្យពាក្យបណ្តឹង**

ថ្នាក់ដឹកនាំស្ថាប័ន ក្រោយពីបានទទួលពាក្យបណ្តឹងជាផ្លូវការ ដែលផ្តល់ជូនដោយការិយាល័យទទួលពាក្យបណ្តឹង ត្រូវបញ្ចេញយោបល់ជាលាយលក្ខណ៍អក្សរលើពាក្យបណ្តឹង រួចបញ្ជូនទៅរដ្ឋបាលក្រោមឱវាទ។ រដ្ឋបាលដែលទទួលបានពាក្យបណ្តឹងដែលមានចំណារឱ្យចាត់ការរបស់ប្រធានស្ថាប័ន ត្រូវរៀបចំតាមបែបបទរដ្ឋបាល និងធ្វើកំណត់បង្ហាញរឿងតាមឋានានុក្រម ដើម្បីបញ្ជូនសំណុំរឿងទៅអង្គភាព ឬអ្នកជំនាញ។ អង្គភាពជំនាញ ត្រូវពិនិត្យសំណុំរឿងឱ្យបានហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយ ដោយត្រូវបញ្ចេញយោបល់ឱ្យសមស្របតាមដំណើររឿង ឬកម្មវត្ថុនៃពាក្យបណ្តឹង ដើម្បីបញ្ជូនទៅថ្នាក់ដឹកនាំ ឬប្រធានស្ថាប័ន ពិនិត្យ និងសម្រេច។ ប្រធានស្ថាប័ន ឬថ្នាក់ដឹកនាំ ត្រូវវាយតម្លៃដោយផ្អែកលើមូលវិចារដែលមានស្រាប់ ហើយត្រូវចេញសេចក្តីសន្និដ្ឋាន ឬសេចក្តីសម្រេចទៅតាមយោបល់ជំនាញសំឡេងភាគច្រើន ប៉ុន្តែគាត់នៅមានអំណាចសម្រេចតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ ការសម្រេចរបស់ប្រធានស្ថាប័ន ឬថ្នាក់ដឹកនាំ មានលក្ខណៈ៣យ៉ាង គឺ៖

- ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ (ក្នុងករណីស្ថាប័នខ្លួនអសមត្ថកិច្ច)
- ត្រូវតម្កល់សំណុំរឿងទុកជាឯកសារ (ក្នុងករណីសំណុំរឿងគ្រាន់តែជាការចម្លងជូនជ្រាប)
- ត្រូវបញ្ជូនទៅជំនាញដើម្បីធ្វើការដោះស្រាយ (ក្នុងករណីជាសមត្ថកិច្ច)។

**ឃ. ការអង្កេតស្រាវជ្រាវ**

ការស៊ើបអង្កេតក្នុងរឿងក្តីរដ្ឋបាល គឺជាការស្វែងរកភស្តុតាង ឬរកសាក្សី ដើម្បីបញ្ជាក់ថា មានការរំលោភច្បាប់ ឬការរំលោភអំណាចពីជនណាមួយដោយបំពាន ឬដើម្បីស្រាវជ្រាវរកហេតុផលនៃការខូចខាត ដើម្បីកំណត់ធ្វើសំណងជួសជុលឡើងវិញទៅតាមទំហំនៃការខូចខាត។ ក្នុងការស៊ើបអង្កេតនេះ អាចមានការជួបជាមួយសាមីជន (ម្ចាស់បណ្តឹង) ជួបជាមួយអាជ្ញាធរដែនដីដែលពាក់ព័ន្ធ និងជួបជាមួយចុងចម្លើយ។ សិទ្ធិក្នុងការស៊ើបអង្កេតត្រូវប្រគល់ដោយប្រធានស្ថាប័ន។

- *ការជួបជាមួយសាមីជន៖* ត្រូវអញ្ជើញម្ចាស់ពាក្យបណ្តឹង ឬត្រូវចុះធ្វើការដល់មូលដ្ឋានរបស់ជនរងគ្រោះរស់នៅ ដើម្បីសាកសួរយកព័ត៌មានបន្ថែមច្បាស់ការ ឬក៏ទាមទារយកភស្តុតាងបន្ថែម ដើម្បីធ្វើឱ្យការស្រាវជ្រាវមានភាពសុក្រឹត បង្ហាញនូវភាពយុត្តិធម៌ពិតប្រាកដ។ ក្នុងជំនួបជាមួយសាមីជននេះ ចាំបាច់ត្រូវធ្វើការស្រាវជ្រាវរកមូលហេតុនៃការប្តឹង ស្រាវជ្រាវរកប្រភព និងដើមកំណើតនៃកម្មវត្ថុដែលគេធ្វើបណ្តឹង ត្រូវសួរជីវប្រវត្តសង្ខេបរបស់សាមីជន រកកម្មសិទ្ធិលើចលនទ្រព្យ ឬរកភស្តុតាងណាដែលមានតម្លៃស្មើដើម្បីការបញ្ជាក់សម្គាល់លើចលនទ្រព្យរបស់ខ្លួន រកសាក្សី ឬអ្នកធានាបើអាចមាន ត្រូវឱ្យសាមីជននិយាយសង្ខេបឡើងវិញ

ពីកម្មវត្ថុនៃពាក្យបណ្ដឹង និងត្រូវក្ដាប់ឱ្យបាននូវសំណូមពរ ឬការទាមទាររបស់សាមីជន លើសំណងក្នុងការខូចខាត ឬការទាមទារសំណងជម្ងឺចិត្ត។

- *ការជួបជាមួយអាជ្ញាធរដែនដី៖* គណៈប្រតិភូស៊ើបអង្កេត ត្រូវចុះទៅដល់មូលដ្ឋានដែលកើតហេតុ ដើម្បីធ្វើការសាកសួរអាជ្ញាធរដែនដីពីព័ត៌មានបន្ថែម។ ការចុះជួបជាមួយអាជ្ញធរដែនដី ចាំបាច់ត្រូវផ្ដល់ព័ត៌មានមកមូលដ្ឋានជាមុន ត្រូវបង្ហាញលិខិតឧទ្ទេសនាម ត្រូវប្រាប់ពីគោលបំណង និងសំណូមពររបស់ប្រតិភូ និងត្រូវធ្វើទំនាក់ទំនងដោយស្មិតស្មាលក្នុងគោលបំណងស្រង់យកការពិត ឬប្រមូលយកភស្តុតាងពិតប្រាកដ។ ក្នុងជំនួបនេះ ប្រតិភូត្រូវស្នើឱ្យអាជ្ញាធរដែនដី ឬស្ថាប័នពាក់ព័ន្ធរៀបរាប់ហេតុការណ៍ដែលបានកើតឡើង មូលហេតុដែលបង្កឡើង និងធ្វើការសំណូមពរឱ្យជួយផ្ដល់ឯកសារភស្តុតាង។
- *ការជួបជាមួយចុងចម្លើយ៖* គឺជាជំនួបដែលពិបាកមួយ។ ប្រតិភូស៊ើបអង្កេតត្រូវពិនិត្យមើលថាតើចុងចម្លើយជាសមូហភាពរដ្ឋ ឬជាបុគ្គលម្នាក់នៃអង្គការរដ្ឋ អង្គការសង្គម ហើយការរំលោភសិទ្ធិ ឬការរំលោភអំណាច បានស្ដែងឡើងជាលក្ខណៈសមូហភាពក្នុងប្រយោជន៍រួម ឬស្ដែងឡើងដោយជនម្នាក់ ឬច្រើននាក់របស់អង្គការរដ្ឋ ក្នុងគោលបំណងដើម្បីប្រយោជន៍ផ្ទាល់ខ្លួន? ប្រតិភូ ត្រូវសុំអនុញ្ញាតជួបជាមួយប្រធានស្ថាប័នរបស់ចុងចម្លើយ ដោយមានលិខិតឧទ្ទេសនាមច្បាស់លាស់ ក្នុងគោលបំណងស្រង់យកព័ត៌មានពិតពីការកើតហេតុ សេចក្ដីបញ្ជាក់ ភស្តុតាង អំណះអំណាង និងសេចក្ដីរាយការណ៍ដទៃទៀតដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់របស់ដើមចោទ។ បន្ទាប់មក ប្រតិភូត្រូវសុំយោបល់ដ៏ខ្ពស់ខ្ពស់ពីប្រធានស្ថាប័នរបស់ចុងចម្លើយ ដើម្បីធ្វើការអនុញ្ញាតទៅជួបជាមួយអ្នកទទួលខុសត្រូវផ្ទាល់ ឬចុងចម្លើយនៅទីកន្លែងកើតហេតុ ឬនៅស្នាក់ការរបស់គេ។ ក្នុងជំនួបនេះ ប្រតិភូត្រូវសាកសួររកឫសគល់ រកដើមហេតុ ដែលបង្កើតឱ្យមានការប្ដឹងផ្ដល់គ្នា ដោយប្រើវិធីសាស្ត្រដូចជួបជាមួយសាមីជន និងអាជ្ញាធរដែនដីដែរ។

### ង. ការសន្និដ្ឋាន និងពិនិត្យវាយតម្លៃ

ការសន្និដ្ឋាន គឺជាដំណាក់កាលចុងក្រោយនៃដំណើរការស៊ើបអង្កេត បន្ទាប់ពីធ្វើការស្រាវជ្រាវបានគ្រប់ឯកសារពាក់ព័ន្ធ មានគ្រប់ភស្តុតាង ដើម្បីបញ្ជាក់បង្ហាញបន្ថែមទៅលើបញ្ហាវិវាទ។ ក្នុងដំណាក់កាលនេះ គេត្រូវស្វែងយល់អំពីច្បាប់ឱ្យគ្រប់ជ្រុងជ្រោយ ពិនិត្យឱ្យល្អិតល្អិតនូវអង្គហេតុជាក់ស្ដែង តាមរយៈព័ត៌មាន និងការបំភ្លឺរបស់សាមីជន ស្ថាប័ន ឬអាជ្ញាធរដែនដីដែលពាក់ព័ន្ធ និងចុងចម្លើយ ដោយធ្វើការប្រៀបធៀបគ្នាឱ្យបានត្រឹមត្រូវ និងប្រុងប្រយ័ត្នបំផុត ក្នុងគោលបំណងសន្និដ្ឋានឱ្យបាននូវការពិតនៃភាពត្រូវ និងខុសរបស់រឿងក្ដី។

ការសន្និដ្ឋាន និងការពិនិត្យវាយតម្លៃនេះ ត្រូវធ្វើជារបាយការណ៍មួយស្ដីពីលទ្ធផលនៃការស៊ើបអង្កេតដែលមានលក្ខណៈច្បាស់លាស់បំផុត ។ របាយការណ៍នេះ នឹងត្រូវដាក់ប្រជុំពិភាក្សាសម្រេចចុងក្រោយដោយគណៈកម្មការដែលទទួលបន្ទុកដោះស្រាយរឿងក្ដី។

### ច. ថេរវេលានៃការដោះស្រាយ

គ្រប់លំដាប់ថ្នាក់នៃស្ថាប័ន ឬអង្គការរដ្ឋ ថេរវេលានៃការដោះស្រាយបណ្ដឹងមានលក្ខណៈខុសគ្នាអាស្រ័យទៅតាមឋានានុក្រម និងប្រភេទនៃពាក្យបណ្ដឹង។ ឧទាហរណ៍ ករណីបណ្ដឹងតវ៉ា ការដោះស្រាយវិវាទនៅថ្នាក់ក្រុង ស្រុក ខណ្ឌ មានរយៈពេលយ៉ាងយូរបំផុត ១ខែ និងនៅថ្នាក់រាជធានី/ខេត្ត មានរយៈពេលយ៉ាងយូរបំផុត ២ខែ។ ចំពោះបញ្ហាដែលស្មុគស្មាញ រយៈពេលនេះអាចត្រូវបានពន្យា តែមិនត្រូវលើស២ដងនៃរយៈ

ពេលដែលបានកំណត់ខាងលើទេ។ ចំពោះ ករណីបណ្ដឹងបរិហារ ដែលជាប្រភេទបណ្ដឹងមានលក្ខណៈស្មុគស្មាញ និងកំបាំងមុខ ដូចនេះ រយៈពេលនៃការដោះស្រាយ ត្រូវដំឡើងទ្វេជាពីរនៃបណ្ដឹងតវ៉ា។

**ឆ. ការពិភាក្សារបាយការណ៍ និងការបញ្ជូនដើម្បីពិនិត្យសម្រេចចុងក្រោយ**

ជាដំណាក់កាលនៃការពិភាក្សាលើរបាយការណ៍លទ្ធផលដែលបានមកពីការស៊ើបអង្កេត ហើយវាគឺជាលទ្ធផលចុងក្រោយនៃការដោះស្រាយរឿងក្ដីវិវាទ។ គណៈកម្មការទទួលបន្ទុកដោះស្រាយរឿងក្ដី ត្រូវបើកការប្រជុំពិភាក្សាទៅលើលទ្ធផលខាងលើ ដោយផ្ដោតយ៉ាងស៊ីជម្រៅទៅលើចំណុចសន្និដ្ឋាន និងចំណុចសំណូមពរ។ ការប្រជុំនេះ ត្រូវសួរយោបល់ពីគ្រប់សមាជិកនៃអង្គប្រជុំក្នុងការសម្រេចវាយតម្លៃបញ្ចប់របាយការណ៍។ ក្រោយពីរបាយការណ៍បានកែសម្រួលរួច តំណាងប្រតិភូស៊ើបអង្កេត ត្រូវអានឱ្យអង្គប្រជុំ (គណៈកម្មការទទួលបន្ទុកដោះស្រាយរឿងក្ដី) បានស្ដាប់ ដើម្បីផ្ដល់យល់ព្រម និងចុះហត្ថលេខាទុកជាបានការ និងទុកជាផ្លូវការ។ របាយ-ការណ៍ផ្លូវការនេះ ត្រូវផ្ញើជូនទៅប្រធានស្ថាប័នក្នុងនាមប្រធានគណៈកម្មការដោះស្រាយ និងប្រធានស្ថាប័នត្រូវផ្ញើក្នុងនាមខ្លួនទៅថ្នាក់ដឹកនាំខ្ពស់បំផុត (នាយករដ្ឋមន្ត្រី) ដើម្បីសុំយោបល់សម្រេចជាកិច្ចបញ្ចប់។

***គួរកត់សម្គាល់ថា៖*** រឿងវិវាទខ្លះមាននីតិវិធីផ្សេងពីនេះ ហើយការសម្រេចក៏ត្រូវធ្វើឡើងត្រឹមគណៈកម្មការដោះស្រាយទំនាស់ដែលបានទទួលសមត្ថកិច្ចតែប៉ុណ្ណោះ គឺមិនចាំបាច់ឆ្លងដល់ថ្នាក់ដឹកនាំខ្ពស់បំផុតទេ ដូចជា *វិវាទទាក់ទងនឹងមុខងារសាធារណៈ* គឺអាចដោះស្រាយ និងសម្រេចត្រឹមគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងមុខងារសាធារណៈ។ ម្យ៉ាងទៀត ទាក់ទងនឹងការចោទប្រកាន់អំពីកំហុសខាងវិន័យលើមន្ត្រីរាជការស៊ីវិល គឺត្រូវមានការស្រាវជ្រាវជាមុនសិន ដោយបង្កើតឡើងនូវគណៈកម្មការស្រាវជ្រាវ ឬក្រុមប្រឹក្សាវិន័យ ដូចដែលមានចែងក្នុងច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល មាត្រា៤៧ ដល់មាត្រា៥០។ រីឯនីតិវិធីដែលត្រូវអនុវត្ត គឺត្រូវគោរពទៅតាមអនុក្រឹត្យស្ដីពីនីតិវិធីនៃការដាក់វិន័យចំពោះមន្ត្រីរាជការស៊ីវិល។

## ៣. ការដោះស្រាយតាមនីតិវិធីរដ្ឋបាលវិវាទ (ឬនីតិវិធីតាមផ្លូវយុត្តាធិការ)

### ៣.១ នីតិវិធីដោះស្រាយតាមយុត្តាធិការធម្មតា (តាមក្រមរដ្ឋប្បវេណី)

ដូចបានដឹងស្រាប់ហើយថា បច្ចុប្បន្នកម្ពុជាមិនទាន់មានក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាល សម្រាប់ដោះស្រាយរឿងក្ដីវិវាទរដ្ឋបាលនៅឡើយទេ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី តុលាការត្រូវតែកាត់ក្ដីរឿងវិវាទរដ្ឋបាលដែលគេប្ដឹងទៅខ្លួន ដើម្បីជៀសវាងការចោទប្រកាន់ពីបទមិនព្រមកាត់ក្ដី ដែលគេហៅថា "យុត្តិនិសេធ"។ ដូចនេះ ក្នុងរឿងក្ដីរដ្ឋបាល ចៅក្រមមុខតែនឹងខំស្វែងរកវិធានដើម្បីកាត់ក្ដី ដោយយកគំរូតាមលំនាំដំណើរការរឿងក្ដីរដ្ឋប្បវេណី និងតាមគោលការណ៍ច្បាប់ដែលមាននៅក្នុងប្រទេសដែលមានបទពិសោធន៍រឹងប៉ឹងខាងនីតិរដ្ឋបាល។ ម្យ៉ាងទៀត តាមរយៈយុត្តិសាស្ត្ររបស់ខ្លួន ចៅក្រមអាចបង្កើតគោលការណ៍ច្បាប់ដែលនឹងមានតម្លៃរហូតដល់មានច្បាប់ថ្មីមកកែប្រែ។ ដូចនេះ សំអាងលើមូលហេតុខាងលើនេះ ចៅក្រមអាចប្រើប្រាស់ក្រមនីតិវិធីរដ្ឋប្បវេណីថ្មី (ឆ្នាំ២០០៦) ដើម្បីធ្វើជាមូលដ្ឋាននៃនីតិវិធីសម្រាប់ការដោះស្រាយវិវាទតាមយុត្តាធិការធម្មតា។

#### ៣.១.១ វគ្គដំបូង ឬការជំនុំជម្រះលើកទីមួយ

ជាដំបូងយើងត្រូវដឹងថា តើតុលាការណាមានសមត្ថកិច្ច? បើយោងតាមមាត្រា៦ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដីនៃរដ្ឋកម្ពុជា បណ្ដឹងខាងវិវាទរដ្ឋបាល ជាគោលការណ៍ត្រូវចាប់ផ្ដើមនៅ

តុលាការខេត្ត/ក្រុង (បច្ចុប្បន្នហៅថា សាលាដំបូងរាជធានី/ខេត្ត)[3]។ ប៉ុន្តែបញ្ហានៅត្រង់ថា តើសាលាដំបូងរាជធានី-ខេត្ត មួយណាដែលមានសមត្ថកិច្ច? ជាទម្លាប់ គឺគេយកតាមទីកន្លែងដែលវិវាទបានកើតឡើង ហើយជួនកាលគេយកទៅតាមកម្មវត្ថុនៃរឿងក្តី ឬអាស្រ័យទៅតាមច្បាប់កំណត់តាមករណីជាយថាប្រភេទ។ ចំពោះក្រមរដ្ឋប្បវេណីថ្មី សមត្ថកិច្ចសាលាជម្រះក្តី គឺកំណត់ទៅតាមលំនៅដ្ឋាន ឬទីសំណាក់ (ករណីគ្មានលំនៅឋាន) របស់រូបវន្តបុគ្គលជាចុងចម្លើយ របស់នីតិបុគ្គលក្នុងប្រទេស និងរបស់នីតិបុគ្គលបរទេស ឬកំណត់ទៅតាមទ្រព្យសម្បត្តិដែលទាមទារឱ្យអនុវត្តកាតព្វកិច្ច ជាដើម។

**ក. ពាក្យបណ្តឹង**

- *លក្ខខណ្ឌនៃបណ្តឹង៖* ពាក្យបណ្តឹងត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងត្រូវមានបញ្ជាក់ពីឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ព្រមទាំងកំណត់នូវកម្មវត្ថុនៃបណ្តឹងឱ្យបានច្បាស់លាស់។
- *ការដាក់ពាក្យបណ្តឹង៖* ពាក្យបណ្តឹងត្រូវដាក់ជូនទៅប្រធានសាលាដំបូងរាជធានី/ខេត្ត(ផ្នែកវិវាទរដ្ឋបាល) នៅការិយាល័យទទួលពាក្យបណ្តឹង ដែលមានក្រឡាបញ្ជីនាយកជាអ្នកត្រួតពិនិត្យ។ បើមេធាវីជាអ្នកដាក់ពាក្យបណ្តឹង មេធាវីអាចចុះហត្ថលេខាលើពាក្យនោះបាន ដោយបន្ថែមចំណារថា "ដោយបានទទួលអំណាច" ក្រោមការទទួលខុសត្រូវរបស់មេធាវីចំពោះកូនក្តីខ្លួន។ បើមានលិខិត ឬឯកសារផ្សេងៗដែលត្រូវភ្ជាប់ ត្រូវដាក់មកជាមួយពាក្យបណ្តឹងតែម្តង។
- *ការទទួលពាក្យបណ្តឹង៖* ក្រឡាបញ្ជីត្រូវចេញបង្កាន់ដៃទទួលលិខិតទាំងនោះ ពីព្រោះមេធាវីត្រូវមានអ្វីសម្រាប់សំអាង ដើម្បីតវ៉ាបើសិនជាមានការបាត់បង់លិខិតភ្ជាប់ណាមួយពីសំណុំរឿងដោយសារទង្វើណាមួយរបស់ក្រឡាបញ្ជី។ ក្រឡាបញ្ជីនាយកគ្មានសិទ្ធិមិនទទួលពាក្យបណ្តឹងទេ ពីព្រោះការសម្រេចស្ថិតនៅលើប្រធានសាលាដំបូងរាជធានី/ខេត្ត ដែលមានសិទ្ធិលើកពាក្យបណ្តឹងចោល។
- *ការពិនិត្យពាក្យបណ្តឹង៖* តុលាការត្រូវពិនិត្យពាក្យបណ្តឹង ដោយអនុលោមទៅតាមរបបគតិយុត្តនៃការទទួលបណ្តឹង ដែលរួមមាន (១) គោលការណ៍ទូទៅនៃភាពមិនអាចទទួលបាននៃបណ្តឹង (២) កាតព្វកិច្ចឧបាស្រ័យបឋម និង (៣) អាជ្ញាយុកាលនៃការធ្វើបណ្តឹង។ ចំណុចទី (១) មានន័យថា តុលាការមិនអាចទទួលបាននៃបណ្តឹងឡើយ ក្នុងករណីដែលមានគោលការណ៍តម្រូវឱ្យអាជ្ញាធររដ្ឋបាលមានកាតព្វកិច្ចត្រូវប្រើប្រាស់អំណាចដែលច្បាប់ប្រគល់ឱ្យ ដូចជា ការចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងពន្ធបន្ថែម២៥ភាគរយនៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់២ភាគរយនៃទឹកប្រាក់បង់ពន្ធយឺតសម្រាប់ខែនីមួយៗ ប្រសិនបើមានការបង់ពន្ធយឺតក្នុងរយៈពេល១៥ថ្ងៃ ក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ[4]។ នេះ គឺជាសមត្ថកិច្ចរបស់អាជ្ញាធររដ្ឋបាល មិនមែនតុលាការទេ។ ចំណុចទី (២) សំដៅថា សម្រាប់ករណីខ្លះដែលច្បាប់តម្រូវឱ្យមានការធ្វើឧបាស្រ័យបឋម នោះតុលាការមិនអាចទទួលបណ្តឹងបាន

[3] មាត្រា៦៖ "តុលាការខេត្ត/ក្រុង មានសមត្ថកិច្ចជំនុំជម្រះបើកផ្លូវឧទ្ធរណ៍នូវរឿងព្រហ្មទណ្ឌ រឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម វិវាទរដ្ឋបាល និងវិវាទការងារ..."។

[4] ច្បាប់ស្តីពីសារពើពន្ធ មាត្រា ១៣២។

ឡើយ ក្នុងករណីដែលកាតព្វកិច្ចឧបាស្រ័យបឋមនោះ មិនទាន់ត្រូវបានបំពេញជាមុនសិន។ ឧទាហរណ៍ អ្នករាជការមានសិទ្ធិប្តឹងតវ៉ាទៅតុលាការអំពីករណីដែលពាក់ព័ន្ធនឹងមុខងារសាធារណៈ ប៉ុន្តែជាការចាំបាច់ អ្នករាជការនោះត្រូវរកវិធីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន ។ ចំពោះ ចំណុចទី (៣)៖ អាជ្ញាយុកាលនៃការធ្វើបណ្តឹង គឺពុំមានការកំណត់ជាទូទៅសម្រាប់រយៈពេលនៃការធ្វើបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធររដ្ឋបាលទៅស្ថាប័នតុលាការឡើយ។ ប៉ុន្តែ មានច្បាប់មួយចំនួនបានកំណត់ពីរយៈពេលនៃបណ្តឹងនេះ ជាក់ស្តែង ការប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្មពាក់ព័ន្ធនឹងម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អាចធ្វើបានក្នុងរយៈពេល ០៣ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។ ផុតរយៈពេលកំណត់នេះ មានន័យថា អ្នកប្តឹងមិនអាចធ្វើការប្តឹងតវ៉ា ឬជំទាស់បានឡើយ។ ដូចនេះ ប្រសិនបើពាក្យបណ្តឹងស្ថិតក្នុងគោលការណ៍ទូទៅនៃភាពមិនអាចទទួលបាននៃបណ្តឹង មិនទាន់បានធ្វើកាតព្វកិច្ចឧបាស្រ័យបឋម ឬហួសអាជ្ញាយុកាលនៃការធ្វើបណ្តឹង នោះតុលាការត្រូវលើកពាក្យបណ្តឹងចោលតាមរយៈសាលក្រម ដោយបញ្ជាក់មូលហេតុថា "អសមត្ថកិច្ច" ឬ "មិនគ្រប់លក្ខណៈច្បាប់" ព្រោះពាក្យបណ្តឹងនោះខ្វះលក្ខខណ្ឌដែលកំណត់ដោយច្បាប់ ឬខុសច្បាប់តែម្តង។ មិនត្រឹមតែប៉ុណ្ណោះ ប្រសិនបើពាក្យបណ្តឹងបំពេញបានតាមលក្ខខណ្ឌច្បាប់រួចហើយ ជាពិសេសលក្ខខណ្ឌទាំងបីខាងលើ ប៉ុន្តែនៅមានចំណុចខ្វះខាត នោះតុលាការនឹងបង្គាប់ឱ្យកែតម្រូវ ហើយប្រសិនបើភាគីបណ្តឹងមិនកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការនឹងលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។

**ខ. ការផ្សះផ្សា**

បើតាមសារាចរលេខ០៤ សរច ៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ របស់ក្រសួងយុត្តិធម៌ស្តីពីសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី នោះការផ្សះផ្សាក្នុងរឿងក្តីរដ្ឋបាលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការខេត្ត/ក្រុងទេ ពីព្រោះសារាចរនោះបានចែង (ក្នុងចំណុច១.អំពីការផ្សះផ្សា) ថា "ប្រសិនបើរឿងក្តីនោះមានលក្ខណៈជារឿងក្តីរដ្ឋបាល ត្រូវផ្ទេររឿងនោះទៅឱ្យអង្គការរដ្ឋបាល ដែលមានសមត្ថកិច្ចដើម្បីដោះស្រាយ"។ បើយោងតាមសារាចរនេះ មានន័យថា ការផ្សះផ្សាត្រូវធ្វើក្នុងក្របខ័ណ្ឌឧបាស្រ័យរដ្ឋបាល ដែលជាលក្ខខណ្ឌមួយចាំបាច់ដើម្បីឱ្យតុលាការអាចទទួលពាក្យបណ្តឹងវិវាទរដ្ឋបាលយកទៅជំនុំជម្រះបាន។ បើទោះជាសារាចរនេះត្រូវបាននិរាករណ៍ដោយក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៦ ហើយក៏ដោយ ក៏ច្បាប់យថាប្រភេទមួយចំនួននៅមានអនុភាពអនុវត្តជាធរមាន ដោយតម្រូវឱ្យមានការធ្វើឧបាស្រ័យបឋមដើម្បីផ្សះផ្សាជាមុនសិន ទើបតុលាការអាចទទួលរឿងក្តីរដ្ឋបាលនោះមកដោះស្រាយបាន។ ឧទាហរណ៍ មាត្រា៥៨ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលនៅជាធរមានរហូតដល់បច្ចុប្បន្ននេះ បានចែងថា "អ្នករាជការមានសិទ្ធិប្តឹងតវ៉ាទៅតុលាការអំពីករណីដែលពាក់ព័ន្ធនឹងមុខងារសាធារណៈ។ ប៉ុន្តែជាការចាំបាច់ អ្នករាជការនោះត្រូវរកវិធីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន"។ មាត្រា៥៩ នៃច្បាប់ដដែលនេះ បានចែងថា "សមត្ថកិច្ចដើម្បីដោះស្រាយទំនាស់ខាងលើ ត្រូវប្រគល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានឈ្មោះថា គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ..."។ ដូចនេះ បើមិនទាន់ឆ្លងការដោះស្រាយពីគណៈកម្មាធិការសម្រុះសម្រួលនេះ

ទេ តុលាការត្រូវបង្វិលសំណុំរឿងមកគណៈកម្មាធិការនេះវិញ ដើម្បីធ្វើការផ្សះផ្សា (សូមមើលចំណុច ក.ពាក្យបណ្តឹង ត្រង់ចំណុចទី៣ ការពិនិត្យពាក្យបណ្តឹង)។

ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៦ ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់បានតម្រូវឱ្យតុលាការធ្វើការសាកល្បងផ្សះផ្សាជាដំបូងសិនមុននឹងបន្តទៅនីតិវិធីបន្ទាប់ លើកលែងតែយល់ឃើញថាមិនសមរម្យ[5]។ មានន័យថា តុលាការអាចធ្វើការផ្សះផ្សារឿងក្តីរដ្ឋប្បវេណីបាន។ ដូចនេះ បើផ្អែកតាមបទប្បញ្ញត្តិនេះ តើតុលាការអាចធ្វើការផ្សះផ្សារឿងរដ្ឋបាល ដូចករណីរឿងក្តីរដ្ឋប្បវេណីបានដែរ ឬទេ?។

**គ. ការអង្កេតស៊ើបសួរ**

ការអង្កេតស៊ើបសួរនៅក្នុងរឿងក្តីរដ្ឋបាល មិនទាន់មានច្បាប់កំណត់នៅឡើយទេ ដូចនេះ ចៅក្រមអាចនឹងធ្វើតាមលំនាំខាងរឿងក្តីរដ្ឋប្បវេណីដែរ។ ក្រៅពីសុំឱ្យភាគីជូនសំអាងតាមដីកាបង្គាប់ឱ្យដាក់មធ្យោបាយតទល់ ឬការពារខ្លួន ចៅក្រមអាចចាត់ឱ្យភាគី ព្រមទាំងសាក្សីទាំងឡាយមកបង្ហាញខ្លួន ដើម្បីស៊ើបសួរ យកចម្លើយផ្ទាល់មាត់ និងតទល់មុខគ្នា ដោយមានមេធាវីចូលរួមផង បើសិនភាគីមានមេធាវីរបស់គេ។ ចៅក្រមអាចចុះផ្ទាល់ដល់ទីកន្លែងដើម្បីស្រាវជ្រាវការពិត។ ដំណើរការនៃការអង្កេតស៊ើបសួរនៅក្នុងនីតិវិធីដោះស្រាយវិវាទតាមផ្លូវយុត្តាធិការនេះ គឺមិនខុសគ្នាពីការអង្កេតស៊ើបសួរនៅក្នុងនីតិវិធីដោះស្រាយវិវាទតាមផ្លូវរដ្ឋបាលឡើយ (សូមមើលចំណុច ២.២ ត្រង់ចំណុច ឃ. ការអង្កេតស្រាវជ្រាវ)។

នីតិវិធីវិវាទរដ្ឋបាល ជានីតិវិធីសរសេរផង បដិវាទកម្មផង និងអង្កេតស៊ើបសួរផ្ទាល់របស់ចៅក្រមផង។

**ឃ. ដំណើរការជំនុំជម្រះ**

ក្នុងខណៈដែលកម្ពុជាបច្ចុប្បន្នពុំទាន់មានក្រមនីតិវិធីរដ្ឋបាល យើងក៏ពុំឃើញមានគោលការណ៍ ឬហេតុផលអ្វីដែលនាំឱ្យចៅក្រមអាចប្រើនីតិវិធីជំនុំជម្រះរបៀបដូចវិវាទរដ្ឋប្បវេណី សម្រាប់ដោះស្រាយរឿងក្តីរដ្ឋបាលដែរ។ ដូចនេះ ដំណើរការជំនុំជម្រះក្នុងរឿងក្តីរដ្ឋបាលមិនអាចសរសេរអ្វីឱ្យបានជាក់លាក់ឡើយនៅទីនេះ។ ប៉ុន្តែ បើតាមក្រមនីតិវិធីរដ្ឋប្បវេណីថ្មី គេឃើញមាននីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ ដែលក្នុងដំណាក់កាលនេះ មានសកម្មភាពជាច្រើនដូចជា ការថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ដែលជាចំណុចរួមនៃវិវាទ ការដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មី (សម្រាប់ករណីពិសេសដូចជា ចំណុចដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ) ការពិនិត្យភស្តុតាងដែលរួមមានភស្តុតាងផ្ទាល់ និងប្រយោល ភស្តុតាងជាមនុស្ស និងជាវត្ថុ ភស្តុតាងស្រប និងផ្ទុយ។ បន្ទាប់មក គឺជាដំណាក់កាលនៃការសម្រេចសេចក្តី។ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការធ្វើសេចក្តីសម្រេចមួយដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ ដែលច្បាប់បានកំណត់ ហៅថា "សាលក្រម"។

**៣.១.២ វគ្គបន្ទាប់ពីការជំនុំជម្រះលើកដំបូង**

ក្រោយពីការជំនុំជម្រះលើកទីមួយរួចហើយ ភាគីអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលបណ្តឹងនេះរួមមាន បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសារទុក្ខទៅតុលាការកំពូល និងបណ្តឹងជំទាស់។ ចំពោះនីតិវិធី គឺអាចព្យាយាមអនុវត្តតាមនីតិវិធីដែលកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីថ្មីឆ្នាំ២០០៦ ចាប់ពីមាត្រា២៥៩ រហូតដល់មាត្រា៣០៦។

**៣.១.៣ ការអនុវត្តសេចក្តីសម្រេច**

[5] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៧ និងមាត្រា១០៤ (ឆ្នាំ២០០៦)។

អាជ្ញាធររដ្ឋបាលត្រូវតែគោរព និងអនុវត្តសេចក្តីសម្រេចរបស់តុលាការ។ ប៉ុន្តែក្នុងរឿងក្តីរដ្ឋបាល រដ្ឋមានសិទ្ធិជ្រើសរើសកាលានុវត្តភាពក្នុងការសងការខូចខាតដែលតុលាការបានសម្រេចឱ្យសង។ តុលាការពុំមានអំណាចបង្ខំឱ្យរដ្ឋសងជាកំហិតនៅថ្ងៃណាមួយជាក់លាក់បានឡើយ។ តុលាការបានត្រឹមដាក់ពិន័យដល់រដ្ឋចំពោះការយឺតយ៉ាវក្នុងការសងការខូចខាតដល់ភាគីឯកជនតែប៉ុណ្ណោះ។

ចុះបើរដ្ឋាភិបាលមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ក្នុងរឿងក្តីរំលោភអំណាចដោយនៅតែអនុវត្តសេចក្តីសម្រេចរដ្ឋបាលដែលខុសច្បាប់ ហើយដែលតុលាការបានប្រកាសមោឃភាពហើយនោះ តើគេមានអ្វីដើម្បីបង្ខំរដ្ឋាភិបាល? បញ្ហានេះ គេមិនដែលប្រទះឃើញក្នុងប្រទេសប្រជាធិបតេយ្យសេរីទេ។ តាមផ្លូវច្បាប់ សេចក្តីសម្រេចរបស់រដ្ឋបាលដែលត្រូវបានតុលាការប្រកាសមោឃភាពហើយនេះ គឺអស់សុពលភាពដើម្បីអនុវត្តតទៅទៀតហើយ។ រដ្ឋសភាក្នុងក្របខ័ណ្ឌនៃអំណាចរបស់ខ្លួនអាចកោះហៅរដ្ឋាភិបាលមកដេញដោល និងបោះឆ្នោតទម្លាក់។

### ៣.២ នីតិវិធីដោះស្រាយតាមយុត្តាធិការពិសេស (ច្បាប់ដោយឡែក)

ការដោះស្រាយវិវាទតាមយុត្តាធិការពិសេស នៅទីនេះ គឺលើកឡើងតែ៣ករណីតែប៉ុណ្ណោះ នោះគឺ (១) វិវាទទាក់ទងនឹងការបោះឆ្នោត (២) វិវាទទាក់ទងនឹងពាណិជ្ជកម្ម និង (៣) វិវាទទាក់ទងនឹងអគ្គិសនី។

#### ៣.២.១ វិវាទទាក់ទងនឹងការបោះឆ្នោត

##### ក. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

យោងតាមមាត្រា១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញ "ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

យោងទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានកំណត់ថា ការដោះស្រាយបណ្តឹងពាក់ព័ន្ធទៅនឹងការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខភាពឈរឈ្មោះបោះឆ្នោត ត្រូវឡើងធ្វើតាមលំដាប់លំដោយ ដែលមានគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មុននឹងអាចធ្វើបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ។ អ្នកដែលចង់ប្តឹងតវ៉ា ឬប្តឹងជំទាស់ពីសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើបណ្តឹងក្នុងរយៈពេល៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីគណៈកម្មាធិការនេះបានចេញសេចក្តីសម្រេច។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង[6]។

ដូចនេះ យើងឃើញថា គ.ជ.ប គឺជាតុលាការជាន់ទាប រីឯក្រុមប្រឹក្សាធម្មនុញ្ញ គឺជាតុលាការជាន់ខ្ពស់សម្រាប់ដោះស្រាយវិវាទដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

##### ខ. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ បានបញ្ជាក់ថា

[6] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាត្រា ៤២ថ្មី។

ការដោះស្រាយវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្នាក់ក្រមជាតិទាំង៣កម្រិត គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតែមួយគត់។

**៣.២.២ វិវាទទាក់ទងនឹងពាណិជ្ជកម្ម**

មជ្ឈត្តកម្មគឺជាវិធានមួយដែលមានដំណើរការជាក់លាក់ចំនួន៦ដំណាក់កាល ដូចដែលបានកំណត់នៅក្នុងច្បាប់ថ្មីស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា ដែលច្បាប់នេះយកលំនាំភាគច្រើនពីច្បាប់គម្រូរបស់ UNCITRAL ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្មអន្តរជាតិ។ ដំណើរការមជ្ឈត្តកម្មទាំង៦ ដំណាក់កាលនោះ មានដូចខាងក្រោមៈ

(១) ការផ្តួចផ្តើមមជ្ឈត្តកម្ម

(២) ការជ្រើសរើសវេទិកាមជ្ឈត្តកម្ម

(៣) នីតិវិធីមុនសវនាការ

(៤) សវនាការមជ្ឈត្តការ

(៥) ការធ្វើសេចក្តីសម្រេចចិត្ត

(៦) ការប្តឹងឧបាស្រ័យ និងការដាក់ឱ្យអនុវត្ត។

លក្ខណៈពិសេសត្រង់ថា វិវាទផ្នែកពាណិជ្ជកម្មត្រូវដោះស្រាយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលមាននីតិវិធីដាច់ដោយឡែកពីក្រមនីតិវិធីរដ្ឋប្បវេណី។ ម្យ៉ាងទៀត ក្នុងដំណាក់កាលទី (៦) ការប្តឹងឧបាស្រ័យ អាចធ្វើទៅបានក្នុងលក្ខខណ្ឌមួយយ៉ាងតឹងរឹងបំផុត ដោយមិនអនុញ្ញាតឱ្យភាគីម្ខាងធ្វើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដោយងាយស្រួលឡើយ ព្រោះវាអាចនឹងធ្វើឱ្យបាត់អត្ថប្រយោជន៍របស់មជ្ឈត្តការ ដែលបានផ្តល់លទ្ធភាពក្នុងការដោះស្រាយវិវាទយ៉ាងឆាប់រហ័ស មានប្រសិទ្ធភាព និងប្រកបដោយលក្ខណៈវិជ្ជាជីវៈ។ លើសពីនេះទៅទៀតប្តឹងឧបាស្រ័យប្រឆាំងនឹងមជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើឡើងទៅសាលាឧទ្ធរណ៍តែម្តង ដោយមិនចាំបាច់ចាប់ផ្តើមពីសាលាដំបូងឡើយ។ ដូចនេះហើយទើបគេហៅថា យុត្តាធិការពិសេស។

ចំពោះដំណើរការលម្អិតនៅក្នុងដំណាក់កាលនីមួយៗ ខាងលើនេះ មានកំណត់នៅក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦។

**៣.២.២ វិវាទទាក់ទងនឹងបញ្ហាអគ្គីសនី**

វិវាទាក់ទងនឹងបញ្ហាអគ្គីសនី ក៏ស្ថិតនៅក្នុងយុត្តាធិការពិសេសដែរ ពីព្រោះវាស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរអគ្គីសនីកម្ពុជា និងអនុវត្តនីតិវិធីនៃការដោះស្រាយទៅតាមច្បាប់ស្តីពីអគ្គីសនីកម្ពុជា។

## ៤. សន្និដ្ឋាន

សរុបសេចក្តីមក ថ្វីត្បិតតែកម្ពុជាពុំទាន់មានក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាលក្នុងការដោះស្រាយរឿងក្តីរដ្ឋបាលក៏ពិតមែន ប៉ុន្តែក្នុងក្របខ័ណ្ឌគតិយុត្តបច្ចុប្បន្ន បានផ្តល់លទ្ធភាពឱ្យមានការដោះស្រាយវិវាទទាក់ទងនឹងរដ្ឋបាល តាមមធ្យោបាយពីរយ៉ាង គឺ (១) ការដោះស្រាយតាមផ្លូវរដ្ឋបាល ដែលក្នុងនោះមានអាជ្ញាធររដ្ឋបាលសាមី និងអាជ្ញាធររដ្ឋបាលឋានានុក្រម និង (២) ការដោះស្រាយតាមផ្លូវយុត្តាធិការ ដែលរួមមានយុត្តាធិការធម្មតា (ប្រើប្រាស់ក្រមនីតិវិធីរដ្ឋប្បវេណី) និងយុត្តាធិការពិសេស (ប្រើប្រាស់ច្បាប់ដោយ

ឡែក) ដូចជា វិវាទទាក់ទងទៅនឹងការបោះឆ្នោត គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញ ។

តែទោះជាយ៉ាងណាក៏ដោយ ក៏ការអនុវត្តជាក់ស្តែងនៅមានការពិបាក ពីព្រោះវិវាទរដ្ឋបាល គឺជាវិវាទដែលកើតឡើងរវាងអាជ្ញាធរសាធារណៈ និងប្រជាពលរដ្ឋ ដែលជាភាគីមានវិសមភាពនៃអំណាចរវាងគ្នា។ ដូច្នេះ ការប្រើប្រាស់ក្រមនីតិវិធីរដ្ឋប្បវេណី ដែលចាត់ទុកភាគីទាំងអស់ដោយស្មើភាពគ្នា ពិតជាមានការពិបាកសម្រាប់ការដោះស្រាយរឿងក្តីរដ្ឋបាល។ ដូចនេះ ទោះចង់ ឬមិនចង់ យូរ ឬឆាប់ កម្ពុជាចាំបាច់ត្រូវតែបង្កើតឱ្យមានក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាល ក្នុងគោលបំណងៈ

- ស្វែងរកយុត្តិធម៌រដ្ឋបាល
- កសាងទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋ
- ពង្រីកនីត្យានុកូលភាពសង្គម
- ការពារផលប្រយោជន៍ និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ
- ធានាសិទ្ធិប្តឹងតវ៉ា និងប្តឹងបរិហាររបស់ប្រជាពលរដ្ឋ និង
- ជាពិសេស ដើម្បីត្រួតពិនិត្យសកម្មភាពរបស់រដ្ឋបាល និងលើកកម្ពស់ការទទួលខុសត្រូវរបស់អង្គការរដ្ឋ ឬអង្គការសង្គម និងមន្ត្រីដែលបម្រើការងាររបស់រដ្ឋទាំងអស់។